សេកកិច្ច នៃ ចំការកម្ម

សេកកិច្ច នៃ ចំការកម្ម

លោក ហ៊ុន សែន គាត់ កំពុង ធ្វើសេកកិច្ច[1] នៃ ចំការកម្ម របស់ គាត់ ដើម្បី បេះផលទុក្ខ សំរាប់ប្រជាពលរដ្ឋខ្មែរ បរិភោគ។ គាត់ មានអារម្មណ៍ ថា បំណាច់[2] របស់គាត់សព្វថ្ងៃ វាជា បារមី នៃ អ្នក មានអំណាច អាចនឹង កាលៃ កម្ម អោយទៅជា បុណ្យ។ ដូចនេះ សញ្ញាណ នៃ បុណ្យបាប របស់គាត់ គឺវាស្ថិត នៅត្រឹមតែ ‹សុខអញ ជាបុណ្យ របស់អញ, ទុក្ខឯង ជាបាប របស់ឯង›។ ចំពោះ លោក ហ៊ុន សែន គំនិត នៃ ករុណា ចំពោះអ្នកទាំងពួង វាជា គំនិត នៃអប្បច្ច័យភាព នៅក្នុង រចនាសម្ព័ន្ធ នៃ ចេស្ដា របស់អំណាច[3]។ ហើយ រចនាសម្ព័ន្ធនេះឯង ដែលគាត់ យកវា មកបញ្ចូល ទៅក្នុង សញ្ញាណ នៃ លទ្ធិប្រជាធិបតេយ្យ។ ម្លោះ ហើយ គាត់ជឿថា អំណាច របស់គាត់ វា ស្របច្បាប់ មាន ចារ នៅក្នុង រដ្ឋធម្មនុញ្ញ។ ដូច្នេះ ការចាប់ ដាក់គុក លោក កឹម សុខា, ហុង សុខហួរ, អ៊ុំ សំអាន ដែលមាន អភ័យឯកសិទ្ធិ ជា សមាជិកសភា វាជាទង្វើស្របច្បាប់ ចំពោះលោក ហ៊ុន សែន។

---

1 ធ្វើសេកកិច្ច : ស្រោច។

2 ពាក្យនេះ មានន័យថាការបានធ្វើអ្វីមួយឲមានថ្វីដៃប្លែកពីអ្នកទាំងពួង។

3 គំនិត នៃអប្បច្ច័យភាព នៅក្នុង រចនាសម្ព័ន្ធ នៃ ចេស្ដា របស់អំណាច ; une pensée illogique dans une structure d'autorité du pouvoir។

សេកកិច្ច នៃ ចំការកម្ម

នៅចំពោះមុខអយុត្តិធម៌នេះ ជនជាតិខ្មែរ មានទុក្ខរួម តែពុំអាចលួតគ្នា ជាបាច់កម្លាំង សំរាប់ការពារ សិទ្ធិពលរដ្ឋ។ តែគេដឹងថា ការរំដោះទុក្ខ វាមានតែទ្រីស្តី ពីរគត់ ដែលត្រូវ យកមកអនុវត្ត : ឬក៏ នាំគ្នាចាប់គ្នាលួត ដោយខ្លួនឯង ជាកម្លាំងរួមងើបឡើង តស៊ូប្រឆាំងនឹងទុក្ខ ឬក៏ មានអ្នកដឹកនាំរវៀសអាចនឹងប្រមូលកម្លាំងជាតិ ជាកម្លាំងលួត ដើម្បីតស៊ូ រំដោះទុក្ខ។ ទ្រីស្តីនោះ វាគ្មានមានសោះ នៅស្រុកខ្មែរសព្វថ្ងៃ ព្រោះប្រជាជនខ្មែរ ក៏ដូច ពួកអ្នកនយោបាយ នាំគ្នាយល់ច្រឡំថានៅស្រុកខ្មែរសព្វថ្ងៃ ជា ស្រុក អនុវត្ត នូវ លិទ្ធិប្រជាធិបតេយ្យបើមិន សុក្រិត ក៏វា ជា សេចក្តីសង្ឃឹមដែរ ដូចយ៉ាង មាន ការបោះឆ្នោត ទៀងទាត់ ជ្រើសរើស អ្នកដឹកនាំជាតិ។ ការបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ នេះឯង ជា ចំការកម្ម ដែលលោក ហ៊ុន សែន គាត់ដាំ, ហើយ គាត់បញ្ឆោតខ្មែរ ក្នុងនោះមាន ទាំង លោក សម រង្ស៊ី និង កឹម សុខា ផង ឲជួយស្រោចឲដំណុះ នៃ ដំណាំ បង្កើតបាន ជាព្រៃកម្ម នៅស្រុកខ្មែរ។ ទាំងអស់គ្នា ដូចជានាំគ្នា បន្សុទ្ធ[4] នូវ សុខ របស់លោក ហ៊ុន សែនដោយ យកទុក្ខខ្លួន ទៅ បន្សាំ នាំ បង្កើន ចំនួន ជនជាតិយួនពេញស្រុកខ្មែរ។ រីឯ ខ្មែរម្ចាស់ស្រុក វិញ ចេះតែលួមជានិច្ច ព្រោះខ្លាច មានទោស ដូចមានចែង នៅក្នុងច្បាប់ រាជនេតិថា : ‹ *ទោសកើតដ្បិតពោល លួមមាត់[5] ឈ្លានពាន*›។ តែ ការហាមចិត្ត

---

[4] បន្សុទ្ធ : ធ្វើអោយសុទ្ធ។

[5] លួមមាត់ មានន័យថា ដែលចេះតែរអិលមាត់ថាទៅ។

សេកកិច្ច នៃ ចំការកម្ម

កុំឲ ‹ល្មមមាត់› វាប្រែក្លាយទៅជា ឲ ‹ចេះតែចិត្តល្មម› ដែលជា និមិត្តហេតុ (symptôme) នៃ ទុក្ខ របស់ខ្មែរតែម្តង។ លុះចំណេរតមក ទុក្ខជាក់ស្តែងនេះ វាក្លាយទៅជា មូលអកុសលខ្មែរ[6] ដោយសារ ចិត្តល្មម វាក្លាយ ជា ពាក្យ វេរចនៈនឹងពាក្យ ប្រតិបាទន៍ ពោលថា : វន្ទា ឆ្ពោះអ្នកមានអំណាច ទោះបី ជននោះជា វសវត្តី[7] ក៏ល្មមនឹងសំពះ សូមរស់ ព្រោះ ឥតវាតអាទិ យកអ្វីទេ។ ដូច្នេះ នាំគ្នា ជជ្រកមមក ទៅ ជួយស្រោច ចំការកម្ម របស់លោក ហ៊ុន សែន ឲដុះ ជាព្រៃកម្ម ជំនួសព្រៃជម្មជាតិ សំរាប់ទុកជា ជំរកកម្ម ក៏ចេះតែចិត្តល្មម នឹងអាចធ្វើបានដែរ អោយតែមានងារ ជាឯកឧត្តម ទោះបីត្រូវ ពួកអ្នកមានអំណាច ជញ្ជាន់ក្បាលក៏ដោយ ដូចលោក សម រង្ស៊ី និង កឹម សុខា គាត់តែងតែប្រព្រឹត្ត អំពើបែបនេះ នៅពេលណា លោក ហ៊ុន សែន ចែកប្រយោជន៏បន្តិចបន្តួចដល់គាត់។ ដូច្នេះ ការណ៏នេះ វាស្របនឹង បុរាណភាសិតថា : ចំណេះ ជិះកឯង។ ពួកគាត់ តែងតែនាំគ្នា ស្រែកបន្លឺថា ជិតំ[8] ! តើ ជិតំ ឥឡូវនៅត្រង់ណាទៅ បើខ្មែរ អ្នកគាំទ្រគាត់ ចេះតែចិត្តល្មមរហូត នាំគ្នា ដេកចាំតែបោះឆ្នោត សំរាប់ ឲយួនជាន់ក នៅក្នុងចំការកម្ម របស់លោក ហ៊ុន សែន ដែល លោក សម រង្ស៊ី និង កឹម សុខា ជួយស្រោច ជានិច្ច៕

---

6 មូលអកុសលខ្មែរ ; racine du mal khmer។

7 វសវត្តី : អ្នកញ៉ាំងគេអោយប្រព្រឹត្តក្នុងអំណាចខ្លួន ឬ អ្នកវាតអំណាច។

8 ជិតំ ពាក្យសំរាប់ស្រែក ឈ្នះហើយ !។